# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

លេខៈ ០៩៧ សខុល

ថ្ងៃអង្គារ ១៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល
## ជម្រាបជូន
## ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

**កម្មវត្ថុៈ** ជំរុញការអប់រំសុខភាពជូនដល់ប្រជាជន និងពង្រឹងការងារតាមដានការអនុវត្តវិធានការការពាររលកទីពីរនៃការចម្លងជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោងៈ** ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលិខិតលេខ ០៨៦ សខល ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងសុខាភិបាល សូមជម្រាបជូនឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ជ្រាបថា ការចម្លងនៃវីរុសកូវីដ-១៩ នៅទូទាំងពិភពលោកបានឈានដល់កម្រិតខ្ពស់ណាស់ គឺមានជាង ៤,៥លាននាក់ដែលឆ្លង និងមានករណីស្លាប់ជាង ៣០ម៉ឺននាក់ បើយោងតាមការវាយតម្លៃហានិភ័យនៃការចម្លង និងរបាយការណ៍ដោយអង្គការសុខភាពពិភពលោក កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០ នេះ។ ស្ថានភាពចម្លងនៅក្នុងតំបន់ ក៏នៅមិនទាន់មានការធូរស្បើយដែរ ដោយសារកំណើននៃការចម្លងវីរុស កូវីដ-១៩ និងការស្លាប់ដោយសារជំងឺនេះ នៅតែបន្តមាននៅឡើយ។

ដូច្នេះ ថ្វីត្បិតតែស្ថានភាពជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ មិនមានរកឃើញករណីឆ្លងថ្មីជាងមួយខែ អ្នកឈឺបានព្យាបាលជាសះស្បើយ ១០០% និងមិនមានករណីស្លាប់ក៏ពិតមែន ហើយភាគច្រើនលើសលុបសុទ្ធសឹងជាករណីនាំចូលមកពីក្រៅប្រទេស ក៏ប៉ុន្តែព្រះរាជាណាចក្រកម្ពុជាត្រូវតែប្រកាន់យកការប្រុងប្រយ័ត្នជាប់ជានិច្ច ចំពោះការប្រឈមទៅនឹងការកើតមានឡើងនូវរលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ ជាពិសេសការចម្លងនៅក្នុងសហគមន៍ ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់នយោបាយ សុខភាពសាធារណៈ សេដ្ឋកិច្ច សង្គម និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទូទៅ ដែលពិបាកធ្វើការប៉ាន់ស្មានបាន។

គួរកត់សម្គាល់ថា វិធានការសុខភាពសាធារណៈចម្បងៗ ដែលបាន និងកំពុងអនុវត្តនៅតាមបណ្តាប្រទេសក្នុងសកលលោក ដើម្បីទប់ស្កាត់ការរាតត្បាតនៃវីរុសកូវីដ-១៩ រួមមានជាអាទិ៍ ការអនុវត្តអនាម័យដៃដោយលាងសម្អាតឲ្យបានញឹកញាប់ (Proper hand hygiene and washing) ការធ្វើចត្តាឡីស័ក (Quarantine)



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧៦

ចំនួន ១៤ថ្ងៃ ការដាក់ឱ្យនៅដាច់ដោយឡែក (Isolation) ការរក្សាគម្លាតសុវត្ថិភាពសង្គម (Social distancing) និងគម្លាតសុវត្ថិភាពបុគ្គល (Physical distancing) ជាដើម ។ល។ ដោយឡែក សម្រាប់ប្រទេសកម្ពុជា យុទ្ធសាស្ត្រចម្បងៗដើម្បីទប់ស្កាត់ការរាតត្បាតនៃវីរុសកូវីដ-១៩ ដែលត្រូវបាន និងកំពុងអនុវត្ត ហើយដែលនៅតែមានសុពលភាពអនុវត្តន៍នៅឡើយនោះ គឺ (១) ការរកឱ្យឃើញបុគ្គលទាំងឡាយណាដែលមានជំងឺកូវីដ-១៩ និងតាមរកបុគ្គលប៉ះពាល់អ្នកជំងឺនោះដោយផ្ទាល់ ឬដោយប្រយោលឱ្យបានរហ័ស (២) ការរាយការណ៍ឱ្យបានលឿនឆាប់រហ័ស (៣) ការដាក់ឱ្យនៅដាច់ដោយឡែកឱ្យបានឆាប់បំផុត និង (៤) ការផ្តល់ការព្យាបាលជាបន្ទាន់នៅក្នុងមន្ទីរពេទ្យរដ្ឋ។

ដើម្បីចូលរួមទប់ស្កាត់រលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា យើងទាំងអស់គ្នាត្រូវតែបន្តអនុវត្តន៍តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងយោងតាមស្មារតីអង្គប្រជុំគណៈកម្មាការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ក្រសួងសុខាភិបាល និងក្នុងនាមជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមធ្វើការណែនាំជូនដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ បន្តចូលរួមការពារហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ និងកាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ច និងសង្គម ដោយអនុវត្តនូវគោលការណ៍ណែនាំសំខាន់ៗដូចតទៅ៖

- បន្តធ្វើឱ្យសកម្មនូវដំណើរការគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត ជាបន្តទៀត
- អាជ្ញាធររាជធានី-ខេត្ត ស្រុក ក្រុង ខ័ណ្ឌ រដ្ឋបាលឃុំ/សង្កាត់ ត្រូវចាត់តាំងកម្លាំងគ្រប់គ្រង ឃ្លាំមើល និងធ្វើការណែនាំអប់រំឱ្យមានការអនុវត្តបានខ្ជាប់ខ្ជួននូវវិធានការការពារការចម្លងជំងឺ ព្រមទាំងជំរុញលើកទឹកចិត្តប្រជាជនក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ឱ្យមានការយល់ដឹង និងអនុវត្តការផ្លាស់ប្តូរកែប្រែទម្លាប់ និងឥរិយាបថនៃការរស់នៅរបស់ខ្លួន ឲ្យស្របតាមរបត់នៃការរស់នៅ "*សកម្មភាពធម្មតាតាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*" ដោយប្រកាន់យកនូវការអនុវត្តអនាម័យដៃស្អាត (លាងដៃញឹកញាប់) ពាក់ម៉ាស់ (ក្នុងករណីចាំបាច់) ប្រើក្រម៉ា ឬក្រដាសជូតមាត់ ខ្ទប់មាត់ពេលមានក្អកកណ្តាស់ បន្តអនុវត្តគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គលជាចាំបាច់
- បន្តហាមឃាត់មិនឱ្យមានការជួបជុំ ឬរៀបចំពិធីណាមួយដែលមានអ្នកចូលរួមច្រើនកុះករពេក ដូចជាការជួបជុំស៊ីផឹកដែលមានគ្នាច្រើន ឬការជួបជុំតាមបែបសាសនាជាដើម រហូតដល់ខែកញ្ញា ឆ្នាំ២០២០ ទើបមានការពិនិត្យឡើងវិញនូវស្ថានភាពនៃការចម្លង និងមានការណែនាំសារជាថ្មី
- ត្រូវតាមដាន និងត្រួតពិនិត្យ តាមភោជនីយដ្ឋាន និងអាហារដ្ឋាន ព្រមទាំងកន្លែងលក់ដូរនានា ដើម្បីឱ្យម្ចាស់ហាងទាំងនោះត្រូវបន្តការអនុវត្តន៍វិធានការការពារការចម្លង ដោយប្រកាន់យកការអនុវត្តអនាម័យដៃស្អាតជានិច្ច ពាក់ម៉ាស់ (ក្នុងករណីចាំបាច់) និងរក្សាគម្លាតសុវត្ថិភាពបុគ្គល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងធានាថាទីតាំងធុរកិច្ចរបស់ខ្លួនមិនក្លាយជាទីកន្លែង

ចម្លងវីរុស-១៩ ដល់អតិថិជន ឬអ្នកបម្រើការនៅទីនោះឡើយ។ ប្រសិនបើមិនអនុវត្តតាមវិធានការទាំងនេះទេនោះ ត្រូវបិទទីកន្លែងធុរកិច្ចនោះជាចាំបាច់ ដើម្បីបញ្ចៀសហានិភ័យនៃរលកទីពីរនៃការចម្លងវីរុសកូវីដ-១៩



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៨ ៨៧៦

- ជំរុញប្រជាពលរដ្ឋមកពីក្រៅប្រទេសដែលមិនបានត្រួតពិនិត្យសុខភាពនៅតាមច្រកព្រំដែន ឱ្យធ្វើចត្តាឡីស័ក និងតាមដានសុខភាពផ្ទាល់ខ្លួនជាចាំបាច់ក្នុងរយៈពេល១៤ថ្ងៃ និងទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិត ប្រសិនបើមានអាការៈមិនស្រួល ឬករណីសង្ស័យ
- ចុះពិនិត្យស្ថានភាពនៅទីកន្លែងស្នាក់នៅរបស់អ្នកចត្តាឡីស័កតាមផ្ទះ ដែលបញ្ជូនមកពីមណ្ឌលពិនិត្យសុខភាពខេត្ត និងពីមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក និងរៀបចំចាត់ចែងការងារបន្តដោយផ្អែកលើលទ្ធផលនៃការតាមដានពិនិត្យ ឲ្យបានហ្មត់ចត់ ជាទីបំផុត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវអនុវត្តឲ្យបានប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងធានាថាទីតាំងដែនសមត្ថកិច្ចរបស់ខ្លួន មិនក្លាយជាទីកន្លែងចម្លងវីរុសកូវីដ-១៩ ដល់ប្រជាពលរដ្ឋ និងចូលដល់សហគមន៍ឡើយ។

សូម ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការរាប់អានពីខ្ញុំ ។

ម៉ម_ប៊ុនហេង

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
"ដើម្បីជូនជ្រាប និងសហការ"
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ


ទីស្តីការក្រសួងសុខាភិបាល អគារលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០